ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ:០២១៤ រ៉ថ:ឥក.ប្រក

# ប្រកាស
# ស្តីពី
# ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ២៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច តួនាទី និងភារកិច្ច និងនីតិវិធីផ្សេងៗក្នុងការអនុវត្តរបស់មន្ត្រីអធិការកិច្ចប្រេងកាត


លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .-

ប្រកាសនេះ មានគោលបំណងធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់ និងដកហូតលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមមាត្រា៦ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត និងមានគោលដៅកំណត់នីតិវិធី បែបបទ និង លក្ខខណ្ឌ ក្នុងការផ្តល់និងដកហូតលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម។

### ប្រការ២ .-

ប្រកាសនេះ មានវិសាលភាពលើការអនុវត្តនូវមុខងាររបស់រដ្ឋបាលរាជធានី ខេត្ត ចំពោះការផ្តល់ និងដកហូតលិខិតអនុញ្ញាតដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ។

### ប្រការ៣ .-

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**លិខិតអនុញ្ញាតប្រព្រឹត្តិកម្ម** សំដៅដល់ការអនុញ្ញាតឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើសកម្មភាពបញ្ចុះសីតុណ្ហភាពដើម្បីពង្រាវឧស្ម័ន ចម្រាញ់ បន្សុទ្ធ ញែក និងលាយបង្កើនគុណភាពនៃប្រេងកាត ផលិតផលប្រេងកាត និងគីមីប្រេងកាត ដែលមានសមត្ថភាពផលិតកម្មសរុបក្រោម ៥ ០០០ ០០០ (ប្រាំលាន) លីត្រ ក្នុង ១ (មួយ) ឆ្នាំ លើកលែងការធ្វើប្រព្រឹត្តិកម្មនៅការដ្ឋានផលិតកម្មប្រេងកាត។

**លិខិតអនុញ្ញាតសន្និធិ** សំដៅដល់ការអនុញ្ញាតឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើសកម្មភាពស្តុកទុកផលិតផលប្រេងកាតនិងគីមីប្រេងកាត នៅទីតាំងលើដី ក្នុងដីនិងកប់ក្នុងដី បណ្តែតទឹក និងក្នុងល្អាង ដោយមានថបនភណ្ឌសម្រាប់ការទទួល ការស្តុក និងការបញ្ចេញ ដែលមានបរិមាណស្តុកចាប់ពី ២០១ (ពីររយមួយ) លីត្រ ដល់ ១៥០.០០០ (មួយរយហាសិបពាន់) លីត្រ ចំពោះប្រេងឥន្ធនៈ និងចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាម ដល់ ៥០.០០០ (ហាសិបពាន់) គីឡូក្រាម ចំពោះឧស្ម័នឥន្ធនៈ។

**លិខិតអនុញ្ញាតដឹកជញ្ជូនក្រៅពីបំពង់បង្ហូរ** សំដៅដល់ការអនុញ្ញាតឱ្យរូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងធ្វើសកម្មភាពដឹកជញ្ជូនផលិតផលប្រេងកាតតាមយានយន្តផ្លូវគោក ដែលមានសមត្ថភាពផ្ទុកចាប់ពី២០១(ពីររយមួយ)លីត្រ ឡើង ក្នុង១(មួយ)លើក ចំពោះប្រេងឥន្ធនៈ ឬចាប់ពី១០១(មួយរយមួយ)គីឡូក្រាម ឡើង ក្នុង១(មួយ)លើក ចំពោះឧស្ម័នឥន្ធនៈ។

**លិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ** សំដៅដល់ការអនុញ្ញាតឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើសកម្មភាពអនុវត្តចំពោះប្រតិបត្តិការស្ថានីយដែលមានសមត្ថភាពស្តុកចាប់ពី ២០១ (ពីររយមួយ) លីត្រ ដល់ ១៥០ ០០០ (មួយរយហាសិបពាន់) លីត្រ ចំពោះប្រេងឥន្ធនៈ និងចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាម ដល់ ៥០ ០០០ (ហាសិបពាន់) គីឡូក្រាម ចំពោះឧស្ម័នឥន្ធនៈ។

**មូលដ្ឋានអាជីវកម្ម** សំដៅដល់ទីតាំងធ្វើសកម្មភាពផ្នែកដោនស្ទ្រីម ឬមណ្ឌលសំចតយានយន្តដឹកជញ្ជូន។

**ប្រការ៤ .-**

ត្រូវបានធ្វើប្រតិភូកម្មដល់រដ្ឋបាលរាជធានី ខេត្ត នូវមុខងារក្នុងការទទួល ពិនិត្យ វាយតម្លៃការស្នើសុំ និងសម្រេចផ្តល់និងដកហូតលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមដូចខាងក្រោម៖

១- លិខិតអនុញ្ញាតប្រព្រឹត្តកម្ម។

២- លិខិតអនុញ្ញាតសន្និធិ។

៣- លិខិតអនុញ្ញាតដឹកជញ្ជូនក្រៅបំពង់បង្ហូរ។

៤- លិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ។

## ជំពូកទី២
## បែបបទនិងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត

**ប្រការ៥ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវទៅដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាមូលដ្ឋានអាជីវកម្មរបស់អ្នកស្នើសុំ។

សំណុំឯកសារពាក្យស្នើសុំដូចមានចែងលម្អិតនៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៦ .-**

ការទទួល ពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមស្របតាមប្រកាសនេះ ត្រូវអនុវត្តតាមយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

អភិបាលរាជធានី ខេត្ត ត្រូវចាត់ឱ្យមានការពិនិត្យនិងផ្ទៀងផ្ទាត់លើសំណើសុំលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ដោយផ្អែកលើវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចេញដោយក្រសួងរ៉ែនិងថាមពល និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតមុននឹងសម្រេច។

**ប្រការ៧ .-**

ដោយអនុលោមតាមនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រោយពីបានទទួលការចាត់តាំងពីអភិបាលរាជធានី ខេត្ត មន្ត្រីបច្ចេកទេសត្រូវចុះដល់ទីតាំងស្នើសុំ ដើម្បីត្រួតពិនិត្យនិងបញ្ជាក់ថាហេដ្ឋារចនាសម្ព័ន្ធផ្នែកដោនស្រ្ទីមឬមធ្យោបាយដឹកជញ្ជូនបម្រើឱ្យសកម្មភាពផ្នែកដោនស្រ្ទីមនោះត្រូវបានរៀបចំនិងដំឡើងត្រឹមត្រូវតាមវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចេញដោយក្រសួងរ៉ែនិងថាមពល។

មន្ត្រីបច្ចេកទេសត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះពិនិត្យនិងផ្ទៀងផ្ទាត់ ដោយមានការសន្និដ្ឋានច្បាស់លាស់ផ្អែកលើទិដ្ឋភាពបច្ចេកទេសសុវត្ថិភាព បរិស្ថាន សេដ្ឋកិច្ចនិងសង្គម សម្រាប់ជាមូលដ្ឋានក្នុងការសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត។

ទម្រង់នៃរបាយការណ៍ពិនិត្យនិងវាយតម្លៃនៃការស្នើសុំលិខិតអនុញ្ញាតទាំងនេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៨ .-**

ការសម្រេចផ្តល់លិខិតអនុញ្ញាតស្របតាមប្រកាសនេះ ត្រូវផ្អែកលើ៖

ក-វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពចេញដោយក្រសួងរ៉ែនិងថាមពល។

ខ- លទ្ធផលនៃការចុះពិនិត្យនិងផ្ទៀងផ្ទាត់របស់មន្ត្រីបច្ចេកទេស។

គ- អនុលោមភាពតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

**ប្រការ៩ .-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើការសម្រេចយល់ព្រមឬបដិសេធលើការស្នើសុំលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីមស្របតាមប្រកាសនេះ ជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំតាមបែបបទនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

ក្នុងករណីរដ្ឋបាលរាជធានី ខេត្ត សម្រេចបដិសេធការផ្តល់លិខិតអនុញ្ញាត រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។

ក្នុងករណីរដ្ឋបាលរាជធានី ខេត្ត សម្រេចផ្តល់លិខិតអនុញ្ញាត រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំឱ្យមានលិខិតអនុញ្ញាតនិងលក្ខខណ្ឌនៃលិខិតអនុញ្ញាតដែលចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់ដែលទទួលបានលិខិតអនុញ្ញាតនោះ។

គំរូលិខិតអនុញ្ញាតនិងលក្ខខណ្ឌនានាមានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ១០ .-**

កម្រៃសេវាសាធារណៈនិងរយៈពេលនៃការផ្តល់សេវា ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១១ .-**

លិខិតអនុញ្ញាតនីមួយៗមានសុពលភាពអចិន្ត្រៃយ៍ លើកលែងត្រូវបានដកហូត។

**ប្រការ១២ .-**

លិខិតអនុញ្ញាតដែលបានផ្តល់ស្របតាមប្រកាសនេះ ត្រូវតម្កល់ទុកនៅរដ្ឋបាលរាជធានី ខេត្តសាមី និងមន្ទីររ៉ែនិងថាមពលរាជធានី ខេត្តសាមី។

**ប្រការ១៣ .-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវត្រួតពិនិត្យជាប្រចាំយ៉ាងតិច ០៦ (ប្រាំមួយ) ខែម្តង ចំពោះការធ្វើសកម្មភាពផ្នែកដោនស្រ្ទីមក្រោមលិខិតអនុញ្ញាតស្របតាមប្រកាសនេះ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីពិនិត្យឃើញថា បុគ្គលដែលទទួលបានលិខិតអនុញ្ញាតស្របតាមប្រកាសនេះបានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌលិខិតអនុញ្ញាត រដ្ឋបាលរាជធានី ខេត្ត ត្រូវណែនាំ ឬក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសដដែល ត្រូវធ្វើការដកហូតលិខិតអនុញ្ញាត។ ក្នុងករណីចាំបាច់ រដ្ឋបាលរាជធានី ខេត្ត ត្រូវរាយការណ៍មកក្រសួងរ៉ែនិងថាមពល ដើម្បីស្នើសុំយោបល់ណែនាំ។

រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីការផ្តល់សេវារដ្ឋបាលស្របតាមប្រកាសនេះ មកក្រសួងរ៉ែនិងថាមពល។

របាយការណ៍នេះ ត្រូវរៀបចំស្របតាមទម្រង់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ប្រការ១៤ .-**

ក្នុងករណីចាំបាច់ មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល អាចចុះពិនិត្យនិងធ្វើអធិការកិច្ចស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ រដ្ឋបាលរាជធានី ខេត្ត ត្រូវសហការនិងសម្រួលឱ្យការចុះពិនិត្យ និងអធិការកិច្ចនេះមានប្រសិទ្ធភាពខ្ពស់។

**ប្រការ១៥ .-**

ក្នុងករណីដែលក្រសួងរ៉ែនិងថាមពលពិនិត្យឃើញថា រដ្ឋបាលរាជធានី ខេត្ត ផ្តល់លិខិតអនុញ្ញាតមិនមានលក្ខណៈសមស្របតាមបញ្ញត្តិនៃប្រកាសនេះ ក្រសួងរ៉ែនិងថាមពលនឹងចេញលិខិតជូនដំណឹងទៅរដ្ឋបាលរាជធានីខេត្តឱ្យធ្វើការដកហូតលិខិតអនុញ្ញាតដែលបានផ្តល់នោះ និងបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

## ជំពូកទី៣
## បែបបទនិងនីតិវិធីនៃការដកហូតលិខិតអនុញ្ញាត

**ប្រការ១៦ .-**

លិខិតអនុញ្ញាតត្រូវបានដកហូតដោយរដ្ឋបាលរាជធានី ខេត្ត ក្នុងករណីណាមួយដូចខាងក្រោម៖

ក- រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាត បានរំលោភបំពានដោយចេតនានិងយ៉ាងធ្ងន់ធ្ងរ លើកាតព្វកិច្ចរបស់ខ្លួន ឬលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ- នីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាត ត្រូវបានប្រកាសក្ស័យធន ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

គ- រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាត បានប្រព្រឹត្តខុសលក្ខខណ្ឌលិខិតអនុញ្ញាត ហើយត្រូវបានណែនាំដដែលៗចំនួន៣(បី)ដង ស្របតាមប្រការ១៣ នៃប្រកាសនេះ។

ឃ- ក្រសួងរ៉ែនិងថាមពលបានជូនដំណឹងដល់រដ្ឋបាលរាជធានី ខេត្ត ឱ្យដកហូតលិខិតអនុញ្ញាតណាមួយដូចមានចែងក្នុងប្រការ១៥ នៃប្រកាសនេះ។

ង- ក្នុងករណីមូលដ្ឋានអាជីវកម្មនេះ ផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ (ដប់ពីរ) ខែ។

**ប្រការ១៧ .-**

នៅពេលចុះត្រួតពិនិត្យឃើញ តាមស្មារតីប្រការ១៣ នៃប្រកាសនេះ ឬទទួលបានព័ត៌មាន ឬពាក្យបណ្តឹងអំពីការប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងប្រការ ១៦នៃប្រកាសនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់មន្ត្រីបច្ចេកទេសចុះធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តអំពើល្មើសនោះ។

ក្នុងករណីបានពិនិត្យឃើញថាមានអំពើល្មើសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីមស្របតាមប្រកាសនេះមែន មន្ត្រីបច្ចេកទេសត្រូវលើកសំណើជូនអភិបាលរាជធានី ខេត្ត ដើម្បីចេញលិខិតព្រមានឱ្យកែកំហុសជាលាយលក្ខណ៍អក្សរ។

ក្នុងករណីរូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនេះ មិនអនុវត្តតាមការណែនាំដូចមានចែងក្នុងលិខិតព្រមានជាលាយលក្ខណ៍អក្សរចំនួន ៣ (បី) ដង ដែលក្នុងមួយដងៗមានរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតព្រមាន មន្ត្រីបច្ចេកទេសត្រូវលើកសំណើជូនអភិបាលរាជធានី ខេត្ត ដើម្បីចេញសេចក្តីសម្រេចស្តីពីការដកហូតលិខិតអនុញ្ញាតនេះ ដោយមានមូលហេតុបញ្ជាក់ច្បាស់លាស់។

គំរូលិខិតព្រមាននិងសេចក្តីសម្រេចស្តីពីការដកហូតលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

**ប្រការ១៨ .-**

ក្រោយពីចេញសេចក្តីសម្រេចស្តីពីការដកហូតលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីមស្របតាមប្រកាសនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវជូនដំណឹងមកក្រសួងរ៉ែនិងថាពលអំពីការដកហូតនេះ ដើម្បីក្រសួងរ៉ែនិងថាមពលចាត់មន្ត្រីជំនាញចុះទៅណែនាំអំពីការរុះរើសម្អាតមូលដ្ឋានអាជីវកម្មនោះតាមលក្ខណៈបច្ចេកទេសសុវត្ថិភាព។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានប្រេងកាត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ នៃប្រកាសលេខ ០២៦៤ រថ.សក.ប្រក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២២ ស្ដីពី ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាត សម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## សំណើសុំ

**លិខិតអនុញ្ញាត**.................................................

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................... ភេទ ........ អាយុ ........ ឆ្នាំ ជនជាតិ .................. សញ្ជាតិ .................. កាន់អត្តសញ្ញាណបណ្ណ - លិខិតឆ្លងដែនលេខ ................................ ថ្ងៃខែឆ្នាំកំណើត .................................. អាសយដ្ឋានបុគ្គលស្នើសុំ .................... ភូមិ ............... ឃុំ/សង្កាត់ ....................... ស្រុក/ខណ្ឌ ................ ខេត្ត/ក្រុង.........................។ លេខទូរស័ព្ទទំនាក់ទំនង .......................... អ៊ីម៉ែល ....................................។

**<u>សូមគោរពជូន</u>**

**ឯកឧត្ដម/លោកជំទាវអភិបាលនៃគណៈអភិបាល**..........................

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលិខិតអនុញ្ញាត.........................................................................................
ដែលមានស្លាកយីហោ ...................... ទីតាំងស្ថិតនៅ........................... ភូមិ ........................
ឃុំ/សង្កាត់ ..............................ស្រុក/ខណ្ឌ .......................... ខេត្ត/ក្រុង ............................។

**<u>យោង</u>** ៖ - ប្រកាសលេខ .................ចុះថ្ងៃទី ..... ខែ ....... ឆ្នាំ ........ របស់ក្រសួងរ៉ែនិងថាមពល ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត

- វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពលេខ..... ចុះថ្ងៃទី........... ខែ............. ឆ្នាំ......... របស់ក្រសួងរ៉ែនិងថាមពល

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំស្នើសុំឯកឧត្ដម/លោកជំទាវអភិបាលនៃគណៈអភិបាល.......................... មេត្តាអនុញ្ញាតឱ្យខ្ញុំបាទ/នាងខ្ញុំធ្វើអាជីវកម្ម................................................................................................................ នៅទីតាំងដូចបានជម្រាបជូនខាងលើ ដោយក្ដីអនុគ្រោះ។

សូមឯកឧត្ដម/លោកជំទាវអភិបាលនៃគណៈអភិបាល ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំបាទ/នាងខ្ញុំ។

**<u>សូមជូនឯកសារភ្ជាប់មកជាមួយនូវ</u>** ៖

១- ពាក្យស្នើសុំលិខិតអនុញ្ញាត.......................................................................................០១ ច្បាប់
២- រូបថតបុគ្គលស្នើសុំ (ទំហំ ៤x៦ រូបថតបច្ចុប្បន្នកាល)............................................... ០៣ សន្លឹក
៣- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ ឯកសារមានតម្លៃស្មើ..................................................០១ ច្បាប់
៤- ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពដែលមានសុពលភាព.........................០១ ច្បាប់
៥- ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល).............. ០១ ច្បាប់
៦- លិខិតប្រគល់សិទ្ធិជាតំណាង (ក្នុងករណីអ្នកស្នើសុំធ្វើជាតំណាងឱ្យនីតិបុគ្គល).................... ០១ ច្បាប់

ថ្ងៃ ...................... ខែ .................... ឆ្នាំ ....................ព.ស.............
........................... ថ្ងៃទី ........ ខែ ................ ឆ្នាំ ២០.......

**ស្នាមមេដៃអ្នកស្នើសុំ**

# ពាក្យសុំលិខិតអនុញ្ញាត

រូបថតបុគ្គលស្នើសុំ
4 x 6

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់អាជីវកម្ម ឬ ប្រធានក្រុមហ៊ុន។

---

**១- អំពីបុគ្គលស្នើសុំ (*)**

☐ រូបវន្តបុគ្គល ☐នីតិបុគ្គល

ឈ្មោះអ្នកស្នើសុំ៖____________________សញ្ជាតិ៖__________ភេទ៖ ☐ ប្រុស ☐ ស្រី

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន :______________ថ្ងៃខែឆ្នាំកំណើត :____________________

អាសយដ្ឋានអ្នកស្នើសុំ :________________________________________________

________________________________________________________________

លេខទូរស័ព្ទទំនាក់ទំនង :____________________________អ៊ីម៉ែល :____________________

| |
|---|
| បំពេញព័ត៌មានខាងក្រោម ប្រសិនបើម្ចាស់អាជីវកម្មជានីតិបុគ្គល<br>តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន៖ ☐ ប្រធានក្រុមហ៊ុន<br>☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង)<br>នាមករណ៍ក្រុមហ៊ុន ៖____________________________លេខចុះបញ្ជីពាណិជ្ជកម្ម :______________<br>អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ :________________________________________<br>លេខទូរស័ព្ទទំនាក់ទំនង :____________________________អ៊ីម៉ែល :____________________ |

**២- អំពីគម្រោងអាជីវកម្ម**

**២.១- ប្រភេទលិខិតអនុញ្ញាត**

- ☐ លិខិតអនុញ្ញាតប្រព្រឹត្តកម្ម
- ☐ លិខិតអនុញ្ញាតសន្និធិ
- ☐ លិខិតអនុញ្ញាតដឹកជញ្ជូនក្រៅបំពង់បង្ហូរ
- ☐ លិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់
    - ☐ ស្ថានីយប្រេងឥន្ធនៈ
    - ☐ ស្ថានីយឧស្ម័នឥន្ធនៈ
    - ☐ ស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ

**២.២- ព័ត៌មានអំពីទីតាំងអាជីវកម្ម**

ឈ្មោះ ឬ ស្លាកយីហោទីតាំងអាជីវកម្ម :________________________________________

អាសយដ្ឋានទីតាំងអាជីវកម្ម :________________________________________________

**៣- ឯកសារភ្ជាប់មកជាមួយ:**

| | |
|---|---|
| ☐ រូបថតម្ចាស់អាជីវកម្ម ៤x៦ | ចំនួន ៣សន្លឹក |
| ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន | ចំនួន ១ ច្បាប់ |
| ☐ ច្បាប់ថតចម្លងវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពដែលមានសុពលភាព | ចំនួន ១ ច្បាប់ |
| ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្នុងករណីជានីតិបុគ្គល) | ចំនួន ១ ច្បាប់ |
| ☐ លិខិតប្រគល់សិទ្ធិជាតំណាង (ក្នុងករណីអ្នកស្នើសុំធ្វើជាតំណាងឱ្យនីតិបុគ្គល) | ចំនួន ១ ច្បាប់ |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។

ថ្ងៃ........................ ខែ.................... ឆ្នាំ.............. ព.ស.........................
............................ ថ្ងៃទី............. ខែ.................. ឆ្នាំ ...............
**ហត្ថលេខា និងឈ្មោះបុគ្គលស្នើសុំ**

សម្រាប់មន្ត្រីទទួលពាក្យ
ឈ្មោះមន្ត្រី៖.........................................
មូលវិចារ៖.............................................

ឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ.......................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........... ស្ដីពី ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាត សម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី/ខេត្ត**......................

..............................................

លេខ:.......................................

**សូមគោរពជូន**
**ឯកឧត្ដម/លោកជំទាវអភិបាលនៃគណៈអភិបាល**..................

**កម្មវត្ថុ៖** របាយការណ៍ស្ដីអំពីលទ្ធផលនៃការពិនិត្យលើឯកសារ និងការចុះពិនិត្យផ្ទៀងផ្ទាត់ទីតាំងអាជីវកម្ម ........................................................... របស់លោក/លោកស្រី ....................... មានស្លាកយីហោ ............................ ស្ថិតនៅ...........................................................................................។

**យោង៖** - លិខិតស្នើសុំ ...........................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្ដម/លោកជំទាវអភិបាលនៃគណៈអភិបាល** មេត្តាជ្រាបថា មន្ត្រីបច្ចេកទេសបានចុះទៅពិនិត្យទីតាំងអាជីវកម្ម........................................... ដែលបានស្នើសុំខាងលើ កាលពីថ្ងៃទី...... ខែ.......... ឆ្នាំ.......... កន្លងទៅនេះ។

១- សមាសភាពក្រុមការងារបច្ចេកទេសចូលរួមពិនិត្យមានដូចតទៅ៖

១) ...........................................................................................................................

២) ...........................................................................................................................

៣) ...........................................................................................................................

៤) ...........................................................................................................................

២- លទ្ធផលនៃការពិនិត្យមានដូចខាងក្រោម៖

១- ស្ថានភាពជាក់ស្ដែងនៃទីតាំងអាជីវកម្ម

- ម្ចាស់ទីតាំងជា ☐ រូបវន្តបុគ្គល ☐ នីតិបុគ្គល
- ☐ គ្រោងរៀបចំ និងធ្វើអាជីវកម្ម ☐ បានរៀបចំ និងកំពុងធ្វើអាជីវកម្ម
- ទំហំទីតាំង ...............ម៉ែត្រក្រឡា (បណ្ដោយប្រវែង............ម៉ែត្រ និងទទឹងប្រវែង........... ម៉ែត្រ)

២- ស្ថានភាពជុំវិញទីតាំង

- ខាងមុខជាប់នឹង: ........................................................................................................
- ចំហៀងខាងស្ដាំជាប់នឹង: ..............................................................................................
- ចំហៀងខាងឆ្វេងជាប់នឹង: .............................................................................................

○ ខាងក្រោយជាប់នឹង: .......................................................................................................

៣- ឯកសារគតិយុត្ត

– លិខិតអង្កេតសុវិធាន-អសុវិធាន ☐ មាន ☐ គ្មាន ☐ ផ្សេងៗ........................
– វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព ☐ មាន ☐ គ្មាន
– .......................................................................................................................

៤- ផ្សេងៗ

– .........................................................
– .........................................................
– .........................................................

**<u>សេចក្ដីសន្និដ្ឋាន៖</u>**

ក្រោយពីបានពិនិត្យលើឯកសារ និងទីតាំងជាក់ស្ដែង ក្រុមមន្ត្រីបច្ចេកទេសបានឃើញថា ទីតាំងអាជីវកម្មនេះ ...............................................................................................................................

*រៀបរាប់ពីស្ថានភាពនៃទីតាំងមានភាពអនុលោម ឬមិនអនុលោម*

..........................................................................។

ដូចនេះ ក្រុមមន្ត្រីបច្ចេកទេសយល់ថា *យោបល់របស់ក្រុមមន្ត្រីបច្ចេកទេស (គួរចេញ ឬមិនគួរ)* ....................................................................។

សេចក្ដីដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម/លោកជំទាវអភិបាលរាជធានី/ខេត្ត** មេត្តាពិនិត្យនិងសម្រេចតាមការគួរ។

សូម **ឯកឧត្តម/លោកជំទាវអភិបាលរាជធានី/ខេត្ត** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ...................... ខែ............ឆ្នាំ................ ព.ស............

....................... ថ្ងៃទី..........ខែ............ឆ្នាំ...............

**មន្ត្រីបច្ចេកទេស**

**ឧបសម្ព័ន្ធទី ៣ នៃប្រកាសលេខ.......................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........... ស្ដីពី**
**ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាត**
**សម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត**
**(ផ្នែកខាងមុខ)**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី/ខេត្ត.............
លេខ:..........................

## លិខិតអនុញ្ញាត

.......................................................

ម្ចាស់អាជីវកម្ម : ...........................................

ប្រភេទអាជីវកម្ម : ...........................................

ឈ្មោះអាជីវកម្ម/ស្លាកយីហោ: ...........................................

អាសយដ្ឋានទីតាំង : ...........................................

ត្រូវបានអនុញ្ញាតឱ្យធ្វើ..............................................ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ដែលប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ និងលក្ខខណ្ឌដូចមានភ្ជាប់ជាមួយនៅផ្នែកខាងខ្នងនៃលិខិតអនុញ្ញាតនេះ។ លិខិតអនុញ្ញាតនេះ មានសុពលភាពអចិន្ត្រៃយ៍ លើកលែងត្រូវបានដកហូត។

ថ្ងៃ...................ខែ...............ឆ្នាំ...............ព.ស............
.................. ថ្ងៃទី.........ខែ.......... ឆ្នាំ២០.....

**អភិបាលរាជធានី/ខេត្ត**

**ឧបសម្ព័ន្ធទី ៣ នៃប្រកាសលេខ.......................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........... ស្ដីពី**
**ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាត**
**សម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត**

**(ផ្នែកខាងក្រោយ)**

ក្នុងរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការនេះ៖

១- ម្ចាស់អាជីវកម្មត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដែលបានផ្ដល់ជូន នៅទីតាំងដែលងាយមើលឃើញក្នុងទីតាំងអាជីវកម្មរបស់ខ្លួន។

២- ម្ចាស់អាជីវកម្មត្រូវមានវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពដែលមានសុពលភាពពីក្រសួងរ៉ែ និងថាមពល មុនពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យសកម្មភាពអាជីវកម្មនេះ ឬក្នុងអំឡុងពេលប្រតិបត្តិការអាជីវកម្មរបស់ខ្លួននេះ។

៣- ម្ចាស់អាជីវកម្មត្រូវប្រតិបត្តិការអាជីវកម្ម ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម សេចក្ដីសម្រេចនេះ បទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

៤- ម្ចាស់អាជីវកម្មត្រូវគោរពតាមសេចក្ដីណែនាំនានារបស់ក្រសួងរ៉ែនិងថាមពល និងរដ្ឋបាលរាជធានី ខេត្ត ក្នុងការដាក់វិធានការ និងបទប្បញ្ញត្តិផ្សេងៗ។

៥- ម្ចាស់អាជីវកម្មត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមករដ្ឋបាលរាជធានី ខេត្ត មុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតដើម្បីគ្រប់គ្រងទីតាំងអាជីវកម្មជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការក្នុងទីតាំងអាជីវកម្មនេះ។

៦- ម្ចាស់អាជីវកម្មត្រូវផ្ដល់ទិន្នន័យបរិមាណផលិតផលប្រេងកាត ដែលបានធ្វើអាជីវកម្មមកឱ្យស្ថាប័នមានសមត្ថកិច្ចតាមការចាំបាច់។

៧- ម្ចាស់អាជីវកម្មត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល រដ្ឋបាលរាជធានី ខេត្ត និងមន្ទីររ៉ែនិងថាមពលរាជធានីខេត្ត ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងទីតាំងអាជីវកម្មមានប្រសិទ្ធិភាពនិងសុវត្ថិភាពខ្ពស់។

៨- ម្ចាស់អាជីវកម្មត្រូវរាយការណ៍មករដ្ឋបាលរាជធានីខេត្ត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការជាធម្មតានៃទីតាំងនេះ។

៩- ក្នុងករណីទីតាំងអាជីវកម្មនេះ ផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ (ដប់ពីរ) ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតនេះនឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

## ឧបសម្ព័ន្ធទី ៤ ភ្ជាប់នឹងប្រកាសលេខ.......................... ចុះថ្ងៃទី......ខែ.........ឆ្នាំ........... ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាត
## សម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត

### របាយការណ៍ស្តីពីការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម

សម្រាប់ឆមាស/ប្រចាំឆ្នាំ....................

| លរ. | ឈ្មោះម្ចាស់អាជីវកម្ម | ទីតាំងអាជីវកម្ម | ប្រភេទអាជីវកម្ម | កាលបរិច្ឆេទចេញ | ទំនាក់ទំនង | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃ............................ ខែ......... ឆ្នាំ................ព.ស............

.............. ថ្ងៃទី........... ខែ...........ឆ្នាំ២០......

អ្នករៀបចំតារាង

បានឃើញ និងឯកភាព

................ ថ្ងៃទី.............ខែ........... ឆ្នាំ២០.....

**អភិបាលរាជធានី/ខេត្ត.............**

ឧបសម្ព័ន្ធទី ៥ ភ្ជាប់នឹងប្រកាសលេខ.......................... ចុះថ្ងៃទី.......ខែ.........ឆ្នាំ........... ស្ដីពី
ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាត
សម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

# លិខិតព្រមាន

## អភិបាលនៃគណៈអភិបាល.......................

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញប្រកាសលេខ .......................... ចុះថ្ងៃទី........ ខែ.......... ឆ្នាំ.............. ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្ដល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- បានឃើញលិខិតអនុញ្ញាតលេខ ................. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់ .....................................
- កំណត់ហេតុស្ដីពីការចុះត្រួតពិនិត្យ.................................................................................................
..........................................................................................................................

## សម្រេច

ឱ្យលោក/លោកស្រីឈ្មោះ.................................. ដែលជាម្ចាស់អាជីវកម្ម...................................
យីហោ........................ ស្ថិតនៅភូមិ............... សង្កាត់/ឃុំ...................ក្រុង/ស្រុក.....................
រាជធានី/ខេត្ត...................................... ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត បទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌនៃលិខិតអនុញ្ញាត.............................................
ដូចខាងក្រោម៖

១- ..........................................................................................................................
..........................................................................................................................

មូលហេតុ៖ ..........................................................................................................
..........................................................................................................................
.........................................................................................................................។

លោក/លោកស្រីឈ្មោះ................................... ត្រូវបញ្ឈប់អំពើល្មើសដែលបានប្រព្រឹត្តរបស់ខ្លួន និងត្រូវអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត បទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌនៃលិខិតអនុញ្ញាត ចាប់ពីថ្ងៃទី............. ខែ......... ឆ្នាំ ......... តទៅ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាបសិប) ថ្ងៃ។

ក្នុងករណី សាមីខ្លួនមិនព្រមកែតម្រូវអំពើល្មើសតាមពេលវេលាកំណត់ខាងលើ រដ្ឋបាលរាជធានី ខេត្ត នឹងអនុវត្តវិធានការតាមនីតិវិធីច្បាប់ជាធរមាន។

ថ្ងៃ.............................ខែ............ឆ្នាំ................ ព.ស...........

............... ថ្ងៃទី.......... ខែ..........ឆ្នាំ...............

**អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត**

# សេចក្តីសម្រេច
# ស្តីពី
# ការដកហូតលិខិតអនុញ្ញាតសម្រាប់ ........................................

## អភិបាលនៃគណៈអភិបាល.......................

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៧៧ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត ផ្នែកដោនស្ទ្រីម
- បានឃើញប្រកាសលេខ ........................... ចុះថ្ងៃទី........ ខែ.......... ឆ្នាំ.............. ស្តីពីការផ្ទេរប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- បានឃើញលិខិតអនុញ្ញាតលេខ ................. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់ ......................................................................................................................
- បានឃើញលិខិតព្រមានលេខ ................. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់ ......................................................................................................................
- កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យ.................................................................................................. ......................................................................................................................

## សម្រេច

ដកហូតលិខិតអនុញ្ញាតលេខ ................. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់លោក/លោកស្រីឈ្មោះ................................ ដែលជាម្ចាស់អាជីវកម្ម.................................................យីហោ ......................... ស្ថិតនៅភូមិ................ សង្កាត់/ឃុំ....................ក្រុង/ស្រុក...................... រាជធានី/ខេត្ត............................................... ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត បទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌនៃលិខិតអនុញ្ញាតស្តីពី................................. ............................................ដូចខាងក្រោម៖

១- ..................................................................................................................................
..................................................................................................................................

២- ..................................................................................................................................
..................................................................................................................................



៥៩

លោក/លោកស្រីឈ្មោះ........................................... ត្រូវបញ្ឈប់សកម្មភាពប្រតិបត្តិការខាងលើ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ។ ជាមួយគ្នានេះ លោក/ស្រីត្រូវធ្វើការរុះរើសម្អាតមូលដ្ឋានអាជីវកម្មរបស់ខ្លួន តាមការណែនាំអំពីលក្ខណៈបច្ចេកទេសសុវត្ថិភាពក្នុងការរុះរើសម្អាតរបស់មន្រ្តីជំនាញនៃក្រសួងរ៉ែនិងថាមពល។

ក្នុងករណី សាមីខ្លួននៅតែបន្តសកម្មភាពប្រតិបត្តិការ....................ទៀត រដ្ឋបាលរាជធានី ខេត្ត នឹងអនុវត្តវិធានការតាមនីតិវិធីច្បាប់ជាធរមាន។

ថ្ងៃ..............................ខែ.............ឆ្នាំ................. ព.ស............

................ ថ្ងៃទី........... ខែ...........ឆ្នាំ................

**អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត**